ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខៈ ៨៥៦ គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ តុលា ឆ្នាំ២០១៦

**គោរពជូន**

**-ឯកឧត្តមប្រធានក្រុមការងារទទួលបន្ទុក និងអនុប្រធានក្រុមការងារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**-ឯកឧត្តមប្រធានក្រុមការងារទទួលបន្ទុក និងអនុប្រធានក្រុមការងារ ក្រសួងមហាផ្ទៃ**

**-ឯកឧត្តមប្រធានក្រុមការងារទទួលបន្ទុក និងអនុប្រធានក្រុមការងារ ក្រសួងមុខងារសាធារណៈ**

**-លោកជំទាវប្រធានក្រុមការងារទទួលបន្ទុក និងអនុប្រធានក្រុមការងារ ក្រសួងកិច្ចការនារី**

**-លោក ប៊ុក សុតន្ធដារ៉ា អគ្គលេខាធិការសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

**កម្មវត្ថុ:** ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកកិច្ចសន្យា និងទីប្រឹក្សាដែលបំពេញការងារក្នុងការអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**យោង:** សៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់ គ.ជ.អ.ប និងកិច្ចសន្យាការងាររបស់បុគ្គលិក ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តម លោកជំទាវជ្រាបថា ផ្អែកតាមការណែនាំដែលមានចែងក្នុងសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់ គ.ជ.អ.ប បានកំណត់ការវាយតម្លៃលើការបំពេញការងាររបស់បុគ្គលិកក្នុងក្របខណ្ឌផអ៣ ដើម្បីពិនិត្យឡើងវិញលើការបំពេញការងាររបស់បុគ្គលិក ដោយធ្វើការផ្ទៀងផ្ទាត់ជាមួយលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ៗ។ ការវាយតម្លៃនេះរួមមានៈ ការវាយតម្លៃការអនុវត្តកិច្ចសន្យាការងារប្រចាំឆ្នាំ និងការវាយតម្លៃការអនុវត្តកិច្ចសន្យាសាកល្បងការងារ ដែលអនុវត្តចំពោះទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យានៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

ក្រសួង ស្ថាប័ននីមួយៗ ត្រូវរៀបចំដំណើរការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកទាំងអស់ ដោយអនុលោមតាមគោលការណ៍ណែនាំដូចភ្ជាប់មកជាមួយ។ ចំពោះការវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សារួមមានៈ ទីប្រឹក្សាជាន់ខ្ពស់ផ្នែកអភិវឌ្ឍសមត្ថភាព និងគោលនយោបាយ ទីប្រឹក្សាអភិវឌ្ឍសមត្ថភាព ទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ ទីប្រឹក្សាគោលនយោបាយតាមដាន វាយតម្លៃ និងដោះស្រាយវិវាទនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ទីប្រឹក្សាគោលនយោបាយសេវាច្រកចេញចូលតែមួយ ទីប្រឹក្សាហិរញ្ញវត្ថុ និងរដ្ឋបាល ទីប្រឹក្សាគោលនយោបាយធនធានមនុស្ស និងទីប្រឹក្សាអភិវឌ្ឍសមត្ថភាពផ្នែកហិរញ្ញវត្ថុ ត្រូវប្រើប្រាស់ទម្រង់បែបបទវាយតម្លៃសម្រាប់ទីប្រឹក្សា (ឧបសម្ព័ន្ធទី១) និងបុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី២-ក)។ បុគ្គលិកកិច្ចសន្យារួមមានៈ បុគ្គលិកជាន់ខ្ពស់ផ្នែកទំនាក់ទំនង និងព័ត៌មានច្រកចេញចូលតែមួយ បុគ្គលិកព័ត៌មានវិទ្យាច្រកចេញចូលតែមួយ បុគ្គលិកគ្រប់គ្រងគេហទំព័រ ជំនួយការរដ្ឋបាល បុគ្គលិកសម្របសម្រួលយេនឌ័រ អគ្គលេខាធិការសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកសម្របសម្រួល និងអ្នកបោសសំអាត ។ ការវាយតម្លៃការបំពេញការងាររបស់អ្នកបើកបរ ត្រូវប្រើប្រាស់ទម្រង់បែបបទវាយតម្លៃសម្រាប់បុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី២-ខ)។ បន្ទាប់មក ក្រសួង

ស្ថាប័ននីមួយៗ ត្រូវរៀបចំរបាយការណ៍សង្ខេបស្ដីពីលទ្ធផលនៃការវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា (ឧបសម្ព័ន្ធទី៤សម្រាប់ទីប្រឹក្សា និងឧបសម្ព័ន្ធទី៥សម្រាប់បុគ្គលិកកិច្ចសន្យា) និងឯកសារវាយតម្លៃការបំពេញការងាររបស់ទីប្រឹក្សា និងបុគ្គលិកកិច្ចសន្យា ដើម្បីបញ្ជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប។

លេខាធិការដ្ឋាន គ.ជ.អ.ប សូមស្នើឯកឧត្តម លោកជំទាវ មេត្តារៀបចំដំណើការវាយតម្លៃការបំពេញការងាររបស់បុគ្គលិកដូចដែលបានកំណត់ខាងលើ ហើយផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប នូវរបាយការណ៍សង្ខេប និងសំណុំឯកសារវាយតម្លៃ ឱ្យបានមុន**ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦** ជាកំណត់។ ដោយឡែក ចំពោះបុគ្គលិកកិច្ចសន្យា និងទីប្រឹក្សាដែលត្រូវបញ្ចប់កិច្ចសន្យាសាកល្បងការងារ ក៏ត្រូវវាយតម្លៃឱ្យបានមុនដំណាច់ខែធ្នូ ឆ្នាំ២០១៦ នេះផងដែរ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវចាត់ចែងអនុវត្តការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់។

សូមឯកឧត្តម លោកជំទាវ មេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**